ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សុន្ទរកថា

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

ក្នុងទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៦
នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ

- សូមថ្វាយបង្គំ ព្រះថេរានុត្ថេរគ្រប់ព្រះអង្គលោកយាយ លោកតា
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងសមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ឬតំណាងអង្គទូតនានា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- លោកឧកញ៉ា អ្នកឧកញ៉ា ប្រធានក្រុមហ៊ុន ប្រធានស្ថាប័ន នាយកសាកលវិទ្យាល័យ វិទ្យាល័យ លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស
- កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ
- តាជី យាយជី និងបងប្អូនជនរួមជាតិជាទីស្នេហា

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ និងភរិយា មានសេចក្តីសោមនស្សរីករាយជាខ្លាំង ដោយបានមកចូលរួមជាអធិបតីក្នុងការប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៦ ដែលកំពុងតែប្រព្រឹត្តទៅយ៉ាងអធឹកអធមនាពេលនេះ ។

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ដើម្បីថ្លែងនូវការកោតសរសើរចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ព្រមទាំងវិស័យឯកជនទាំងឡាយ ដែលតែងបានប្រឹងប្រែងរួមគ្នាដោះស្រាយបញ្ហាចំពោះមុខដោយមិនខ្លាចនឿយហត់ ពុះពារប្រឆាំងដាច់ខាតទៅនឹងសកម្មភាពរបស់ឧក្រិដ្ឋជនស្របទៅតាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ជាការពិតណាស់ ប្រសិនបើមិនមានការប្រឹងប្រែងទេនោះ អំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ច រំលោភបំពាននឹងកាន់តែសកម្មកាន់តែឃោរឃៅ និងរីករាលដាលច្រើនឡើង។ រីឯប្រជាពលរដ្ឋកាន់តែច្រើននឹងជួបគ្រោះមហន្តរាយ ហើយ

សង្គមជាតិ នឹងមិនមានសេចក្ដីសុខ និងស្ថេរភាពបានឡើយ ។ ជនល្មើសបានសាងបាបកម្មទៅលើមនុស្សដូចគ្នា តាំងពីកូនក្នុងផ្ទៃរហូតដល់មនុស្សចាស់ជរា ឥតកោតញញើត និងសាហាវឃោរឃៅជាងសត្វតិរិច្ឆានទៅទៀត ធ្វើយ៉ាងណាឲ្យតែវាអាចចម្រាញ់បាននូវផលប្រយោជន៍ ។ យើងនឹងមិនត្រូវអត់អោនឲ្យពួកវាបានឡើយ ហើយត្រូវតែអនុវត្តនីតិវិធីផ្ដន្ទាទោសតាមច្បាប់ដែលបានកំណត់ឲ្យបានត្រឹមត្រូវ ។

ទោះបីជាអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើមនុស្ស អំពើហិង្សាផ្លូវភេទលើស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ បញ្ហាគ្រឿងញៀន និងបទល្មើសមួយចំនួន ត្រូវបានទប់ស្កាត់ បង្ក្រាប និងផ្ដន្ទាទោសជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏បញ្ហាទាំងអស់នេះនៅតែកើតមានជាហូរហែ និងតាមរូបភាពប្លែកៗ ដែលបង្កើតជាកង្វល់សម្រាប់រាជរដ្ឋាភិបាលទាំងមូល និងប្រជាពលរដ្ឋគ្រប់ទីកន្លែង។ នេះជាមូលហេតុដែលទាមទារឲ្យយើងទាំងអស់គ្នា ត្រូវបន្តយកចិត្តទុកដាក់ ខិតខំប្រឹងប្រែងពុះពារ រួមគ្នាជម្នះការលំបាក ឧបសគ្គ និងខិតខំដោះស្រាយ បញ្ហាជាឫសគល់ទាំងឡាយឲ្យអស់ ដើម្បីកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមាន ។

**ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ និង ជនរួមជាតិជាទីស្នេហា**

សព្វថ្ងៃនេះ ជនល្មើសបាន និងកំពុងតែប្រើគ្រប់មធ្យោបាយលួងលោម បោកបញ្ឆោត បង្ខិតបង្ខំ រំលោភបំពាន ធ្វើទារុណកម្ម ដើម្បីកេងប្រវ័ញ្ចទាញយកផលប្រយោជន៍លើកម្លាំងពលកម្ម ផ្លូវភេទ ដកហូតសរីរាង្គ និងរហូតដល់អាយុជីវិតរបស់មនុស្ស គ្រប់ភេទ គ្រប់វ័យ ទាំងទារកនៅក្នុងផ្ទៃ រហូតដល់មនុស្សចាស់ជរា យ៉ាងសាហាវ ឃោរឃៅ បង្កនូវទុក្ខវេទនា ឈឺចាប់ខ្លោចផ្សា ព្រោះតែបានខូចខាតដល់សុខភាពរាងកាយ ផ្លូវចិត្ត ស្មារតី និង សេដ្ឋកិច្ច យ៉ាងធ្ងន់ធ្ងរហួសពិព៌ណ៌នា ។នេះគឺជា សោកនាដកម្មថ្មីមួយទៀត ចំពោះមនុស្សជាតិ ដែលបង្កដោយមនុស្សដូចគ្នា ។

កត្តាចម្បងដ៏ធំមួយចំនួនដែលបង្កើតឲ្យមានបទល្មើសទាំងឡាយសព្វថ្ងៃនេះគឺ «**កង្វះសីលធម៌ក្នុងការរស់នៅ**»។បន្តិចម្តងៗមនុស្សបានបាត់បង់នូវសីលធម៌ មិនចេះអាណិតអាសូរអាត្មានិយម លោភលន់មិនស្កប់ស្កល់ និងមិនខ្វាយខ្វល់ពីការឈឺចាប់របស់អ្នកដទៃ ទើបមនុស្ស អាចធ្វើនូវអំពើដ៏ស្មោកគ្រោក សាហាវឃោរឃៅបែបនេះបាន ។ «**គ្រឿងញៀនស្រវឹង**» ក៏ជាថ្នាំពុល ដែលបានពង្វក់ស្មារតីឲ្យមនុស្សបាត់បង់សតិវិចារណញ្ញាណ និងហ៊ានប្រព្រឹត្តទង្វើជាបាបកម្មគ្រប់រូបភាពដោយគ្មានក្រែងរអែងអ្វីឡើយ ។ «**ការផ្ដល់ព័ត៌មានមិនត្រឹមត្រូវ**» ថែមទាំងការឃោសនាបំផ្លើសអំពីផលប្រយោជន៍មិនពិត បានទាក់ទាញប្រជាពលរដ្ឋមួយចំនួនឲ្យប្រថុយប្រថានផ្សងព្រេង មិនគិតពីគ្រោះថ្នាក់ ដើម្បីឲ្យគេបានរំលោភបំពាន និងកេងប្រវ័ញ្ចយ៉ាងងាយស្រួល ។

មួយវិញទៀត «**ការអនុវត្តច្បាប់**» របស់យើង ក៏នៅមិនទាន់រឹងមាំគ្រប់គ្រាន់នៅឡើយ ព្រោះបណ្ដាញជនល្មើស និងមេខ្លោងមួយចំនួន មិនទាន់ត្រូវបានវែកមុខ និងយកមកផ្ដន្ទាទោសឲ្យសក្តិសមនៅឡើយ ហើយនៅតែមានឱកាសបន្តប្រព្រឹត្តបទល្មើសទាំងនោះជាបន្តបន្ទាប់ និងកាន់តែធ្ងន់ធ្ងរទៅៗ ។ជនល្មើសពិតជាឆ្លាតវាងវៃ ចេះប្រើឱកាស «**ភាពចន្លោះប្រហោងនៃច្បាប់**» និង «**កង្វះខាតនៃបុគ្គលជាមន្ត្រីខិលខូច**» ខ្លះឲ្យចូលរួម

បម្រើមហិច្ឆិតារបស់ពួកវាបាន ។ យើងមិនអាចធ្វេសប្រហែស បណ្តែតបណ្តោយ ព្រងើយកន្តើយ មិនខ្វាយខ្វល់នឹងចំណុចខ្វះចន្លោះទាំងអស់នេះបានឡើយ ហើយត្រូវតែកែលម្អជាបន្ទាន់ ព្រោះវានឹងបន្តបំផ្លាញដល់មនុស្សជាតិ ប្រទេសជាតិ និងពិភពលោក ឲ្យវិនាសមិនខានឡើយ ។

សព្វថ្ងៃនេះ កម្លាំងសមត្ថកិច្ចយើងជាច្រើន បានខិតខំប្រឹងប្រែង មិនខ្លាចនឿយហត់ និងពេលខ្លះរហូតលះបង់អាយុជីវិត ដើម្បីបុព្វហេតុសន្តិសុខ សុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិ ។ តែទោះបីជាយ៉ាងនេះក្តី ក៏នៅតែមិនទាន់មានឥទ្ធិពលគ្រប់គ្រាន់ អាចលុបបំបាត់បទល្មើសទាំងអស់នេះបាននៅឡើយ ។ យើងនៅតែទាមទារឲ្យមានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធ ដែលមិនអាចមាននរណាម្នាក់ ស្ថាប័នណាមួយ ឬប្រទេសណាមួយអាចលុបបំបាត់បទឧក្រិដ្ឋជួញដូរមនុស្សតែម្នាក់ឯងបានឡើយជាពិសេស ឧក្រិដ្ឋកម្មឆ្លងដែនដែលមានខ្សែបណ្តាញចាត់តាំងយ៉ាងស្មុគស្មាញបែបនេះ ។ ដើម្បីធ្វើកិច្ចការនេះ ទាមទារឲ្យមានការយល់ដឹងដូចគ្នា មានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ ដើម្បីអនុវត្តភារកិច្ចប្រកបដោយការទទួលខុសត្រូវ និងរួមសហការគ្នាជាផ្លូងមួយ ឆ្ពោះទៅកាន់គោលដៅរួមតែមួយ គឺ **«ធ្វើអ្វីៗដើម្បីសេចក្តីសុខ និងភាពរីកចម្រើនរបស់មនុស្សជាតិ»** ។

រាជរដ្ឋាភិបាល នៅតែបន្តថែទាំកម្លាំងពលកម្ម ដែលជាជាធនធានដ៏មានតម្លៃរបស់ជាតិ និងបានរិះរកគ្រប់មធ្យោបាយ ក្នុងការបង្កើតឲ្យមានបរិស្ថានរស់នៅ និងការងារល្អ ចំណូលល្អនៅក្នុងស្រុក ក៏ដូចជានៅក្រៅប្រទេស ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋតាមគ្រប់មធ្យោបាយ ។ យើងបានខិតខំលើកកម្ពស់ការទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងសមស្រប ទៅនឹងការខិតខំប្រឹងប្រែងធ្វើការងារ ការប្រើប្រាស់ជំនាញ បច្ចេកទេស និងគំនិតច្នៃប្រឌិតរបស់ពលរដ្ឋដើម្បីចូលរួមអភិវឌ្ឍប្រកបដោយចីរភាព និងធានានូវកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៃសេដ្ឋកិច្ច សុវត្ថិភាព និងស្ថេរភាពសង្គម ។ រាជរដ្ឋាភិបាល បានផ្តល់ជម្រើសជូនប្រជាពលរដ្ឋ ដោយខិតខំស្វែងរកទីផ្សារការងារនៅក្រៅប្រទេសបន្ថែមទៀត ក្នុងប្រទេសដែលមានកិច្ចព្រមព្រៀងជាមួយគ្នា ដោយបានជ្រើសរើស និងបញ្ជូនចេញទៅធ្វើការងារល្អៗនៅទីនោះជាបន្តបន្ទាប់ ។

កន្លងមក រាជរដ្ឋាភិបាលក៏ដូចជាដៃគូពាក់ព័ន្ធ បានខិតខំ បង្ការទប់ស្កាត់ តាមរយៈការអប់រំផ្សព្វផ្សាយ គ្រប់រូបភាព គ្រប់ទីកន្លែង តាមគ្រប់មធ្យោបាយ តែទន្ទឹមនឹងនោះ ក៏មានការផ្សព្វផ្សាយដោយបណ្តាញក្រុមទុច្ចរិតមួយចំនួន ដែលនៅតែអាចបោកប្រាស់ប្រជាពលរដ្ឋឲ្យលង់ខ្លួន ខាតបង់លុយកាក់ និងធ្លាក់ខ្លួនរងគ្រោះបាន ។ ដូច្នេះ ក្នុងការបង្ការទប់ស្កាត់ ទាមទារឲ្យមានការបង្កើតជាជម្រើសសម្រាប់ការរស់នៅរបស់គ្រួសារបន្ថែមទៀត និងតាមដានសកម្មភាពក្រុមហ៊ុនទុច្ចរិតមួយចំនួនដែលមិនមានការទទួលខុសត្រូវ ឲ្យប្រឈមមុខជាមួយច្បាប់ ។ ទីភ្នាក់ងារមុខរបរ និងការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានស្វែងរកកិច្ចសហការជាមួយបណ្តារោងចក្រសហគ្រាស និងម្ចាស់អាជីវកម្មទាំងឡាយ ដើម្បីផ្តល់ព័ត៌មានអំពីទីផ្សារការងារ និងមុខរបរសមស្របជូនដល់ប្រជាពលរដ្ឋដែលមានតម្រូវការ ។ យើងបានបើកទូលាយឲ្យមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជននានា ដើម្បីឲ្យប្រជាពលរដ្ឋយើង ជាពិសេសយុវជន ស្ត្រី និងកុមារទទួលបានព័ត៌មាន ចំណេះដឹង បច្ចេកទេស និងជំនាញបំណិនជីវិត ដើម្បីអាចការពារខ្លួនពីកលល្បិចជនល្មើសដែលតែងតែព្យាយាមអូសទាញឲ្យធ្លាក់ចូលក្នុងការកេងប្រវ័ញ្ច អំពើជួញដូរមនុស្ស និងការប្រព្រឹត្តបទល្មើសផ្សេងៗ ។ ចំពោះ

ជនរងគ្រោះ រាជរដ្ឋាភិបាល បានសហការជាមួយអង្គការដៃគូមួយចំនួនដែលមានទិសដៅរួមគ្នា ជួយផ្តល់កិច្ចការពារ និងសេវាសមស្របនានា ដើម្បីធានាសុវត្ថិភាព និងការពារមិនឲ្យទទួលរងភាពរងគ្រោះជាថ្មី ។

ជាការពិតហើយដែលថា ការជ្រើសរើសពលករឲ្យទៅធ្វើការងារតាមប្រព័ន្ធស្របច្បាប់ នៅមិនទាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋយើងនៅឡើយ ព្រោះសេចក្តីត្រូវការ មានទំហំធំជាងការផ្គត់ផ្គង់ តែរាជរដ្ឋាភិបាល ក៏មិនចង់ឲ្យពលករយើងប្រថុយប្រថាន ផ្សងព្រេងនឹងគ្រោះថ្នាក់ច្រើនរាប់មិនអស់ រហូតទទួលរងនូវទុក្ខវេទនា ឈឺចាប់ ខ្លោចផ្សារ ជរាពិការ បាត់បង់សមត្ថភាពពលកម្ម និងរហូតដល់បាត់បង់អាយុជីវិត គួរឲ្យសោកស្តាយនោះឡើយ ។ នេះមិនមែនជាដំណោះស្រាយក្នុងការលើកកម្ពស់ជីវភាពឡើយ ផ្ទុយទៅវិញ សកម្មភាពនេះ បាននិងកំពុងតែបង្កនូវគ្រោះមហន្តរាយដល់ប្រជាពលរដ្ឋ គ្រួសារ និងសង្គមជាតិ ។

ក្រសួងពាក់ព័ន្ធ សមត្ថកិច្ច និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ចាំបាច់នូវរិះរកនីតិវិធីក្នុងការកែលម្អស្ថានភាពនេះជាបន្ទាន់ រួមទាំងការដោះស្រាយបញ្ហាប្រជាពលរដ្ឋដែលកំពុងមានតម្រូវការមូលដ្ឋាន ដើម្បីសម្រួលដល់ការរស់នៅ និងមានឱកាសបង្កើតការងារមុខរបរល្អៗនៅក្នុងស្រុក ជិតផ្ទះសម្បែង បានថែទាំកូនចៅ ដីស្រែចម្ការ ច្បារដំណាំ និងបង្កើនចំណូលជាប្រចាំ មិនចាំបាច់រងគ្រោះ និងរងការប្រមាថមើលងាយដូចសព្វថ្ងៃនេះឡើយ ។ មិនតែប៉ុណ្ណោះ ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ គប្បីតាមដាន ត្រួតពិនិត្យ ដោយយកចិត្តទុកដាក់ ដោះស្រាយបញ្ហាដែលកើតមានតាមមុខសញ្ញា នៃការទទួលខុសត្រូវរបស់ខ្លួនឲ្យបានល្អ និងជម្រុញការផ្តល់សេវាចាំបាច់ឲ្យដល់ដៃប្រជាពលរដ្ឋទាន់ពេលតាមតម្រូវការ ជៀសវាងការទុកឲ្យបញ្ហាកាន់តែស្មុគស្មាញ ដែលអាចជម្រុញឲ្យប្រជាពលរដ្ឋប្រឈមនឹងហានិភ័យដោយចំណាកស្រុក និងអំពើជួញដូរមនុស្ស ។ បង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងលំហូរចេញចូល នៃជនទេសន្តរប្រវេសន៍ តាំងពីក្នុងមូលដ្ឋានរហូតដល់តាមខ្សែបន្ទាត់ព្រំដែន ទាំងដែនទឹក ដែនគោក និងដែនអាកាស ព្រមទាំងតាមដានឃ្លាំមើលសកម្មភាពគួរឲ្យសង្ស័យរបស់ជនល្មើស ដើម្បីបង្ការ និងបង្ក្រាបឲ្យទាន់ពេលវេលា ។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវ ដល់បណ្តាប្រទេសពាក់ព័ន្ធទាំងអស់ ដែលបាន ចុះហត្ថលេខារួមគ្នាលើអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គប្បីជម្រុញការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ និងរួមគ្នាពិនិត្យលើចំណុចខ្វះខាតនៃការអនុវត្ត ហើយរួមគ្នាកែលម្អឲ្យបានទាន់ពេលវេលា ។ ជាពិសេសប្រទេស ដែលទទួលពលករកម្ពុជា សូមរក្សាការសន្យាក្នុងកិច្ចព្រមព្រៀង ដែលគូសបញ្ជាក់អំពីការទទួលយកពលករស្របច្បាប់ពីកម្ពុជា និងសូមមេត្តាជួយថែទាំកម្លាំងទាំងនោះ ដូចពលរដ្ឋរបស់ខ្លួន ព្រមទាំងជួយការពារពីការរំលោភបំពាន កេងប្រវ័ញ្ច ដែលអាចកើតមានជាយថាហេតុ ក្នុងប្រទេសរបស់អស់លោក ។ ក្នុងករណីដែលពលករកម្ពុជា បានប្រព្រឹត្តខុសឆ្គង សូមមេត្តាអប់រំ ឬបញ្ជូនត្រឡប់មកកម្ពុជាវិញតាមផ្លូវច្បាប់ ជាជាងការធ្វើទារុណកម្ម ឬសម្លាប់យ៉ាងអាណោចអធម្ម ។

ជាថ្មីម្តងទៀត ខ្ញុំសូមរំលឹក ដាស់តឿនចំពោះមន្ត្រីរាជរដ្ឋាភិបាលទាំងឡាយ ដែលបាន និងកំពុងតែសាងបញ្ហា ឃុបឃិត និងសហការជាមួយជនល្មើសជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយ

ទោះបីដោយចេតនាក្តី អចេតនាក្តី ត្រូវឆាប់ដកខ្លួនជាបន្ទាន់ និងកែខ្លួនឲ្យបានល្អ ព្រោះមិនអាចសំងំលាក់លៀមសកម្មភាពទាំងនេះបានទៀតឡើយ ហើយនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់ ។

ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងក្នុងនាមគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រកាសជាឱឡារិកក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦នេះ ចំពោះមុខសហគមន៍ជាតិ និងអន្តរជាតិ នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបញ្ជាក់យ៉ាងច្បាស់ជាថ្មីទៀតថា៖

- រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ និងការលំបាកគ្រប់បែបយ៉ាងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ដើម្បីឲ្យប្រជាជនកម្ពុជា និងមនុស្សជាតិ ទទួលបានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់ និងភាពសុខដុមរមនា ។
- រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្ត រួមសហការជាមួយបណ្តាដៃគូពាក់ព័ន្ធនានា និងទាមទារឲ្យមានកិច្ចសហការកាន់តែជាក់លាក់ពីបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយក្នុងតំបន់ និងលើពិភពលោក ដើម្បីរួមគ្នាបង្ក្រាបអំពើជួញដូរមនុស្ស គ្រប់រូបភាព និងផ្តន្ទាទោសជនល្មើសឲ្យបានម៉ឺងម៉ាត់ដើម្បីកាត់បន្ថយ និងលុបបំបាត់ប្រសិទ្ធភាពបទល្មើស ។
- រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តខិតខំប្រឹងប្រែងពង្រឹងការអនុវត្តច្បាប់ អនុសញ្ញា កតិកាសញ្ញាអន្តរជាតិ ច្បាប់ជាតិ អនុស្សរណៈ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ផែនការសកម្មភាពរួម និងផែនការជាតិ ព្រមទាំងបទដ្ឋានគតិយុត្តិទាំងឡាយដែលមានស្រាប់ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ និងបំពេញបន្ថែម តាមការចាំបាច់ ។
- រាជរដ្ឋាភិបាល នឹងបន្តគាំទ្រ និងលើកកម្ពស់កិច្ចខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់លំដាប់ថ្នាក់ឲ្យមានលទ្ធភាព សមត្ថភាព និងធនធានគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចរបស់ខ្លួនឲ្យបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ និងភរិយា សូមប្រគេនពរស័ព្ទសាធុការចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមឧទ្ទិសបួងសួងដល់គុណព្រះរតនៈត្រ័យ បារមី វត្ថុស័ក្តិសិទ្ធិ សូមប្រទានពរជ័យ សិរីមង្គលវិបុលសុខគ្រប់ប្រការ ជូនឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ លោក លោកស្រី នាងកញ្ញា ក្មួយៗ បងប្អូនជនរួមជាតិ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ**

**សូមអរគុណ**